# គោលធម៌

# ឧត្តមវិបស្សនា


រៀបរៀងដោយ

**គណៈកម្មាធិការពុទ្ធមណ្ឌលវិបស្សនាធុរៈ**

**នៃព្រះរាជាណាចក្រកម្ពុជា**



ផ្សាយចេញពី

**ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា**

**( ភ្នំអដ្ឋរស្ស ) ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល**



រក្សាសិទ្ធិ



ព.ស. គ.ស.

# ធម្មទាន

## ឧបាសិកា សុខ-អ៊ីម ព្រមទាំងបុត្រ ត្វូ-ឆែគៀង
## បានបោះពុម្ពសៀវភៅ គោលធម៌ ឧត្តមវិបស្សនា
## លើកទី ចំនួន ក្បាល
## នេះសម្រាប់ជាធម្មទានជូនដល់ពុទ្ធបរិស័ទទូទៅ។

សូមឧទ្ទិសមហាកុសលនេះជូនចំពោះបុព្វការីជនមាន មាតាបិតា ជីដូនជីតា និងគ្រូឧបជ្ឈាយាចារ្យមួយអន្លើដោយ ពពួកញាតិក្នុងសង្សារវដ្តគ្រប់ៗគ្នា។

សូមអស់លោកដ៏មានគុណទាំងអស់នោះ អញ្ជើញទទួលអនុមោទនាត្រេកអរ ហើយសូមបានសម្រេចនូវឧត្តមប្រយោជន៍ ព្រមទាំងបានសោយសុខក្នុងសុគតិភពមានព្រះនិព្វានជាអវសាន កុំបីឃ្លៀងឃ្លាត ទៅជាប្រការដទៃឡើយ។

បោះពុម្ពលើកទី ថ្ងៃទី ខែ

ព.ស. គ.ស.

# <u>អារម្ភកថា</u>

- យោងតាម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចេញឆ្នាំ ១៩៩៣។
- យោងតាម ព្រះរាជក្រឹត្យតែងតាំងសម្ដេចព្រះសង្ឃរាជ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩១។
- យោងតាមសំណូមពរ របស់អនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី៥ ពីថ្ងៃទី២ ដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៦។
- យោងតាមសេចក្ដីសម្រេច នៃការចាត់តាំងគណៈកម្មាធិការផ្នែកវិបស្សនាធុរៈ របស់សម្ដេច - ព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជគណៈមហានិកាយ ចុះថ្ងៃទី២៦ ខែសីហា គ.ស.១៩៩៦។

គណៈកម្មាធិការផ្នែកវិបស្សនាធុរៈបានរៀបចំ

**ច្បាប់វិបស្សនា** មាន៣ថ្នាក់គឺ

- **បឋមវិបស្សនា ១**
- **មធ្យមវិបស្សនា ១**
- **ឧត្តមវិបស្សនា ១**

- ច្បាប់បឋមវិបស្សនានិងមធ្យមវិបស្សនា ខ្ញុំព្រះករុណា អាត្មាភាព បានរៀបចំរួចស្រេចជាស្ថាពរហើយ ក្នុងទីនេះសូមរៀបរៀងនូវ **គោលធម៌ឧត្តមវិបស្សនា** បន្ត ដោយមានគោលបំណងចង់ឱ្យ ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ពុទ្ធបរិស័ទទូទៅ គ្រប់វ័យ គ្រប់ជាន់ថ្នាក់ ដែលបានសិក្សាវិបស្សនាថ្នាក់បឋមនិងមធ្យមចប់ហើយសិក្សាបន្ថែម ដើម្បីធ្វើឱ្យចំណេះវិជ្ជាផ្នែកខាងវិបស្សនាធុរៈនោះបានរីកចម្រើនរុងរឿងខ្លាំងឡើង និងធ្វើឱ្យចិត្តរបស់អ្នកសិក្សារីងរឹត

បរិសុទ្ធវិសេសជាង និងធ្វើឱ្យជាក់ច្បាស់នូវគុណមានឈានអភិញ្ញា និងមគ្គផលជាលោកុត្តរនិងដើម្បីតាំងទុកនូវសាសនាព្រះបរមគ្រូផ្ទែកវិបស្សនាធុរៈ ឱ្យបានថ្កុំថ្កើងរុងរឿង និងបង្កើនសាមគ្គីធម៌សេចក្ដីស្ងប់កាយវាចាចិត្តនៃសាធុជនទាំងឡាយ កម្ចាត់បង់នូវភាពហិង្សាដែលជាទីនាំមកនូវសេចក្ដីវិនាសគ្រប់យ៉ាង ឱ្យបានសេចក្ដីសុខសន្តិភាពទូទៅក្នុងលោកទាំងមូលអស់កាលជាអង្វែងតរៀងទៅ។

| ល.រ | មាតិកាធម៌ | ទំព័រ |
| --- | --- | --- |
| ១ | រូបសមាបត្តិ៤ឬ៥ក្នុងកម្មដ្ឋាន១១ គឺកសិណ១០ អានាបាណស្សតិ១.. | ១១ |
| ២ | ហាត់សមាបត្តិ៨ ឱ្យស្ទាត់ដោយវសីទាំង៥ | ១៦ |
| ៣ | សិក្សាអំពីទស្សនៈសមាបត្តិ៤ | ១៨ |
| ៤ | ការកំណត់ដឹងរូបធម៌និងនាមធម៌ក្នុងអតីត | ២០ |
| ៥ | ការកំណត់ដឹងនូវនាមរូបខាងក្រៅ | ២០ |
| ៦ | ការកំណត់ដឹងនូវនាមរូបក្នុងអតីត អនាគត បច្ចុប្បន្ន | ២២ |

| | | |
|---|---|---|
| ៧ | ការកំណត់ដឹងនូវហេតុបច្ច័យ<br>របស់នាមរូប | ៤៧ |
| ៨ | ការប្រតិបត្តិឃើញព្រះត្រៃលក្ខណ៍<br>ដោយអំណាចកលាបសម្មសនញ្ញាណ<br>និងឧទយព្វយានុបស្សនាញាណ | ៥៨ |
| ៩ | វិបស្សនូបក្កិលេស ១០ ឬ ៣០<br>និងការលះបង់ដោយត្រៃលក្ខណ៍ | ៦៩ |
| ១០ | ប្រតិបត្តិតាមវិបស្សនាញាណ ៩ | ៧១ |
| ១១ | អរិយសច្ច ៤ | ៧២ |
| ១២ | មគ្គ៤  ផល៤  និព្វាន១,២,៣ | ៧៥ |
| ១៣ | បច្ចវេក្ខណញាណ ១៩ | ៧៩ |
| | សិក្សាអំពីកិលេសនិងធម៌បន្ថែម | ៨១ |

# កម្មវិធីសិក្សាវិបស្សនាថ្នាក់ឧត្តម
# គោលធម៌ឧត្តមវិបស្សនា
# មាតិកា មានចំនួន ១៣

I. **ក-រូបសមាបត្តិ ៤ ឬ ៥** ក្នុងកម្មដ្ឋាន ១១គឺ កសិណ ១០ អានាបានស្សតិ១

**ខ-រូបសមាបត្តិ** ៣ ឬ ៤ ក្នុង **កម្មដ្ឋាន** ៣ គឺ មេត្តាព្រហ្មវិហារ ១ ករុណាព្រហ្មវិហារ ១ មុទិតាព្រហ្មវិហារ ១

**គ-អរូបសមាបត្តិ** ទី៤ ឬទី៥ ក្នុង ឧបេក្ខាព្រហ្មវិហារ ១

**ឃ-អរូបសមាបត្តិ** ៤ក្នុង អរូប្បកម្មដ្ឋាន ៤

II. ហាត់នូវ **សមាបត្តិ ៨** ឱ្យស្ទាត់ដោយ **វសី** ទាំង៥

III. សិក្សាអំពី **ទស្សនៈសមាបត្តិ ៤**

IV. ការកំណត់ដឹងនូវ **រូបធម៌** និង**នាមធម៌** ក្នុងអតីត

V. ការកំណត់ដឹងនូវ **រូប** និង **នាម** ខាងក្រៅ

VI. **ក-ការកំណត់ដឹងនូវ នាមរូប ក្នុងអតីត-អនាគត-បច្ចុប្បន្ន**-ក្នុង-ក្រៅ-គ្រោតគ្រាត-ល្អិត-ថោកទាប- បណីត-ឆ្ងាយ-ជិត-មិនមែនសត្វ-បុគ្គលមនុស្ស-ទេវតាជាដើម ។

**ខ**-ការសិក្សាអំពីអារម្មណ៍របស់ **វិបស្សនា** បន្ត។

VII. ការកំណត់ដឹងនូវហេតុបច្ច័យរបស់ **នាមរូប** ឬ **បញ្ចក្ខន្ធ** ដែលប្រព្រឹត្តទៅក្នុងកាលទាំង៣ ។

VIII. ការប្រតិបត្តិឃើញ **ព្រះត្រៃលក្ខណ៍** ដោយអំណាច **កលាបសម្មសនញ្ញាណ** និង **ឧទយព្វយានុ-**

បស្សនាញាណ។

IX. វិបស្សនូបក្កិលេស ១០ និង៣០ និងការលះបង់
    ដោយត្រៃលក្ខណ៍

X. ប្រតិបត្តិតាមវិបស្សនាញាណ៩

XI. អរិយសច្ច ៤

XII. មគ្គ៤ ផល៤ ព្រះនិព្វាន ១-២-៣

XIII.បច្ចវេក្ខណញ្ញាណ១៩

- **សិក្សាអំពីកិលេស និង ធម៌បន្ថែម**

**១-នីវរណៈធម៌ ៥ កិលេស ៣ ឧបក្កិលេស១៦**

**២-អនុសយកិលេស ៧**

**៣- សំយោជនកិលេស ១០**

**៤-អវិជ្ជា ៨ តណ្ហា ១០៨** ។ល។ និង ។ល។

**៥-បហាន ៣**

**៦-ពោធិបក្ខិយធម៌ ៣៧ មានសតិបដ្ឋាន៤ ។ល។**

និង ។ល។

## បំបែកគោលធម៌ ឧត្តមវិបស្សនា

I-ក) - **រូបសមាបត្តិ ៤** ឬ **៥** ក្នុង **កម្មដ្ឋាន ១១** គឺ

**កសិណ ១០ អានាបាណស្សតិ១**

**- រូបសមាបត្តិ ៤** នោះបានដល់ **រូបាវចរជ្ឈាន**

ជា **ឈានចតុក្កន័យ** ហ្នឹងឯង។

**រូបាវចរជ្ឈាន ៤ នោះ គឺ** បឋមជ្ឈាន ១, ទុតិយជ្ឈាន១, តតិយជ្ឈាន១, ចតុត្ថជ្ឈាន១,

**-បឋមជ្ឈាន** ឈានទី១មានអង្គ៥ គឺវិតក្កៈ១, វិចារៈ១, បីតិ១, សុខៈ១, ឯកគ្គតា១។

**-ទុតិយជ្ឈាន** ឈានទី២ មានអង្គ៣ គឺ បីតិ១, សុខៈ១, ឯកគ្គតា១ ។

**-តតិយជ្ឈាន** ឈានទី៣ មានអង្គ២ គឺ សុខៈ១, ឯកគ្គតា១, ។

**-ចតុត្ថជ្ឈាន** ឈានទី៤ មានអង្គ២ គឺ ឧបេក្ខា១, ឯកគ្គតា១ ។

( សេចក្តីប្រែរបស់អង្គឈានទាំងនេះមានក្នុង គោលធម៌មធ្យមវិបស្សនា)

**រូបសមាបត្តិ** ៥នោះ បានដល់រូបាវចរជ្ឈាន៥ ជាឈាន **បញ្ចកន័យ** ហ្នឹងឯង ។

**រូបាវចរជ្ឈាន ៥ នោះ គឺ**

១- **បឋមជ្ឈាន** មានអង្គ ៥ គឺ វិតក្កៈ១ វិចារៈ១

បីតិ១ សុខៈ១ ឯកគ្គតា១,។

**២-** **ទុតិយជ្ឈាន** មានអង្គ៤ គឺ វិចារៈ១ បីតិ១ សុខៈ១ ឯកគ្គតា១

**៣-** **តតិយជ្ឈាន** មានអង្គ៣ គឺ បីតិ១ សុខៈ១ ឯកគ្គតា១

**៤-** **ចតុត្ថជ្ឈាន** មានអង្គ២ គឺ សុខៈ១ ឯកគ្គតា១។

**៥-** **បញ្ចមជ្ឈាន** មានអង្គ២ គឺ ឧបេក្ខា១ ឯកគ្គតា១។

**-កម្មដ្ឋាន១១** គឺ **កសិណ១០ អានាបាណស្សតិ១**

## កសិណ១០ គឺ

បឋវីកសិណ១ អាបោកសិណ១ តេជោកសិណ១ វាយោកសិណ១ នីលកសិណ១ បីតកសិណ១ លោហិតកសិណ១ ឱទាតកសិណ១ អាកាសកសិណ១

អាលោកកសិណ១ និង អានាបាណស្សតិ១ ជាគម្រប់១១។

ឯសេចក្តីប្រែមានក្នុងគោលធម៌មធ្យមវិបស្សនា។

**ខ) -រូបសមាបត្តិ** ៣ ឬ ៤ ក្នុង **កម្មដ្ឋាន** ៣ គឺ មេត្តាព្រហ្មវិហារ ១ ករុណាព្រហ្មវិហារ ១ មុទិតាព្រហ្មវិហារ ១។ ព្រហ្មវិហារ ៣ នេះមានសេចក្តីប្រែ ក្នុងគោលធម៌មធ្យមវិបស្សនាហើយ។

**គ) -រូបសមាបត្តិ** ទី៤ ឬ ទី៥ ក្នុង **ឧបេក្ខាព្រហ្មវិហារ** នោះ **ឧបេក្ខា** គឺផ្សាយ **ឧបេក្ខា** ដល់សត្វទាំងអស់។

**ឃ) -អរូបសមាបត្តិ** ៤ ក្នុង **អរូប្បកម្មដ្ឋាន**នោះ បានដល់ **អរូបាវចរជ្ឈាន** ៤ ហ្នឹងឯង។

## អរូបាវចរជ្ឈាន ៤ នោះគឺ

**១-អាកាសានញ្ចាយតនជ្ឈាន** មានអង្គ២ គឺឧបេក្ខា១, ឯកគ្គតា១

**២-វិញ្ញាណញ្ចាយតនជ្ឈាន** មានអង្គ២ គឺ ឧបេក្ខា១, ឯកគ្គតា១

**៣-អាកិញ្ចញ្ញាយតនជ្ឈាន** មានអង្គ២ គឺ ឧបេក្ខា១, ឯកគ្គតា ១

**៤-នេវសញ្ញានាសញ្ញាយតនជ្ឈាន** មានអង្គ២ គឺ ឧបេក្ខា១, ឯកគ្គតា ១

**អារុប្ប ៤គឺ**

**១-អាកាសានញ្ចាយតនៈ** យកអាកាសក្នុងបដិភាគនិមិត្ត ដែលកើតអំពីកសិណ លើកអាកាសកសិណ

ចេញ ដែលមិនមានទីបំផុតមកជាអារម្មណ៍។

**២-វិញ្ញាណញ្ចាយតនៈ** ស្រាវយកអរូបវិញ្ញាណទី១ដែលផ្សាយទៅមិនមានទីបំផុតមកជាអារម្មណ៍។

**៣-អាកិញ្ចញ្ញាយតនៈ** កំណត់យកអរូបវិញ្ញាណទី១ដែលផ្សាយទៅមិនមានកង្វល់តិចតួចមកជាអារម្មណ៍។

**៤-នេវសញ្ញានាសញ្ញាយតនៈ** កំណត់យកសេចក្តីល្អិតរបស់អរូបវិញ្ញាណទី៣ ដែលមានស្ទើរតែនឹងមិនមានមកជាអារម្មណ៍។

( ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ១-២ )

II-ហាត់នូវ **សមាបត្តិ៨** ឱ្យស្ទាត់ដោយ **វសី** ទាំង៥

- **សមាបត្តិ ៨** បានដល់ឈាន៨ ហ្នឹងឯង

**ឈាន៨ នោះគឺ**

**រូបាវចរជ្ឈាន ៤** និង **អរូបាវចរជ្ឈាន ៤**

***វសី*** គឺជាភាពដែលថ្នឹក ឬស្ទាត់ជំនាញមាន ៥យ៉ាងគឺ

**១-អាវជ្ជនវសី** ថ្នឹកក្នុងវិធីនឹករកនូវអង្គរបស់ ឈាន,

**២-សមាបជ្ជនវសី** ថ្នឹកក្នុងវិធីនឹងចូលកាន់ឈាន,

**៣-អធិដ្ឋានវសី** ថ្នឹកក្នុងវិធីទប់ទុកនូវឈាន,

**៤-វុដ្ឋានវសី** ថ្នឹកក្នុងវិធីចេញចាកឈាន,

**៥-បច្ចវេក្ខណវសី** ថ្នឹកក្នុងវិធីពិចារណានូវអង្គរបស់ឈាន។ **សមាបត្តិ** ទាំង៨ ដែលនឹងប្រព្រឹត្តទៅតាំងនៅ ដោយប្រពៃ គឺព្រះយោគីហាត់ឱ្យស្ទាត់ដោយ **វសី** ទាំង៥នេះ។ (ដកពីវិសុទ្ធិមគ្គភាគ១-២)

## III- **សិក្សាអំពីទស្សនសមាបត្តិ ៤**

**ទស្សនៈសមាបត្តិ ៤ នោះគឺ**

១- ពិចារណាឃើញរាងកាយទាំងមូល ពេញដោយអាការ៣២ មានសក់ជាដើមប្រកបដោយ**បដិកូលភាព**

២- ពិចារណាឃើញរាងកាយទាំងមូល ពេញដោយអាការ៣២,មានសក់ជាដើមប្រកបដោយ**បដិកូលភាព** ហើយពិចារណាឃើញនូវពណ៌សម្បុររបស់អាការមានស្បែកសាច់ជាដើមថែមទៀត ។

៣- ពិចារណាឃើញរាងកាយទាំងមូល ពេញដោយអាការ៣២មានសក់ជាដើម ថែមប្រកបដោយ**បដិកូលភាព** ហើយពិចារណាឃើញនូវពណ៌សម្បុរអាការ មានស្បែក សាច់ជាដើម និងដឹងច្បាស់នូវ

វិញ្ញាណសោតរបស់បុរស ដែលមិនដាច់ចេញជា ២ចំណែក តាំងនៅក្នុងលោកនេះ១ផ្នែក, តាំងនៅក្នុងបរលោក១ផ្នែក ។

៤- ពិចារណាឃើញរាងកាយទាំងមូល ពេញដោយអាការ៣២ មានសក់ជាដើមប្រកបដោយ**បដិកូលភាព** ហើយពិចារណាឃើញនូវពណ៌សម្បុររបស់អាការ មានស្បែកជាដើម និងដឹងច្បាស់នូវវិញ្ញាណសោតរបស់បុរសដែលមិនដាច់ចេញជា២ចំណែក គឺមិនតាំងនៅក្នុងលោកនេះ១ផ្នែក មិនតាំងនៅក្នុងបរលោក១ផ្នែក ។ (ដកពីសុត្តន្តបិដកទីឃនិកាយបញ្ញមភាគ បាដិកវគ្គ ១៨ សម្បសាទនីយសូត្រ)

## IV- **ការកំណត់ដឹងនូវរូបធម៌និងនាមធម៌ក្នុងអតីត**

**នាមរូប** ក្នុងអតីតនោះ សំដៅយកនាមរូបដែលប្រព្រឹត្តទៅក្នុងអតីតជាតិ (ជាតិកន្លងរួចហើយ)។

**នាមរូប**នេះគឺព្រះយោគី គប្បីដឹងច្បាស់ដោយអំណាចនៃ **បុព្វេនិវាសានុស្សតិញ្ញាណ** គឺប្រាជ្ញាដែលរលឹកឃើញនូវ **ខន្ធបញ្ចក** ដែលអាស្រ័យនៅហើយក្នុងកាលមុន (ជាតិមុន)។ **បុព្វេនិវាសានុស្សតិញ្ញាណ** មាន **ចតុត្ថជ្ឈាន** ឬ **បញ្ចមជ្ឈាន** ជាជើងទ្រ។

(ដកពីគម្ពីរវិសុទ្ធិមគ្គភាគ២-៣)

## V- **ការកំណត់ដឹងនូវនាមរូបខាងក្រៅ**

**នាមរូប** ដែលស្ថិតនៅព្ធដ៏ខាងក្រៅអំពីអត្តភាពនៃខ្លួននេះ នាមរូបនោះតែងមានក្នុងលោកទាំង៣ និងកាលទាំង៣។

**លោក៣ នោះគឺ**

**១- កាមលោក** បានដល់ **អបាយភូមិ** ៤ជាន់

**មនុស្ស** ១ **ទេវតា** ៦ជាន់ ។

**២-រូបលោក** បានដល់ **រូបព្រហ្ម** ១៦ជាន់ ។

**៣-អរូបលោក** បានដល់ **អរូបព្រហ្ម** ៤ជាន់ ។

**កាល៣ នោះគឺ**

**១-អតីតកាល** កាលកន្លងទៅហើយ

**២-បច្ចុប្បន្នកាល** កាលកំពុងកើតឡើងប្រាកដ

**៣-អនាគតកាល** កាលមិនទាន់មកដល់ ។

**នាមរូប** ទាំងនេះ គឺព្រះយោគី គប្បីដឹងច្បាស់ប្រាកដដោយអំណាច **ចុតូបបាតញ្ញាណ** ប្រាជ្ញាដឹងនូវ**ចុតិ** និង **បដិសន្ធិ** របស់សត្វ ។

ញាណនេះ មានចតុត្ថជ្ឈាន ឬ បញ្ចមជ្ឈានជាជើងទ្រ ។
(ដកពីគម្ពីរវិសុទ្ធិមគ្គភាគ២-៣)

VI- **ការកំណត់ដឹងនូវនាមរូប ក្នុងអតីត អនាគត បច្ចុប្បន្ន ក្នុង ក្រៅ គ្រោតគ្រាត ល្អិត ថោកទាប ថ្លៃថ្លា ឆ្ងាយ ជិត** មិនមែន សត្វ បុគ្គល មនុស្ស ទេវតា ជាដើម ។

**ក–រូបមាន ២៨គឺ**

មហាភូតរូប ៤, ឧបាទាយរូប ២៤ ។

**មហាភូតរូប ៤** នោះគឺ

បឋវីធាតុ១, អាបោធាតុ១, តេជោធាតុ១, វាយោធាតុ១ ។

**ឧបាទាយរូប ២៤** នោះមានដូចតទៅគឺ

**បសាទរូប ៥** គឺ

ចក្ខុបសាទ១, សោតបសាទ១, ឃានបសាទ១,

ជិវ្ហាបសាទ១, កាយបសាទ១ ។

**វិស័យរូប ៤** គឺ

រូបារម្មណ៍១, សទ្ទារម្មណ៍១, គន្ធារម្មណ៍១,

រសារម្មណ៍១ ។

**ភាវរូប ២** គឺ

ឥត្ថិភាវរូប១, បុរិសភាវរូប១ ។

**ហទយរូប១, ជីវិតរូប១, អាហាររូប១, បរិច្ឆេទរូប១**

**វិញ្ញត្តិរូប ២** គឺ

កាយវិញ្ញត្តិ ១ វចីវិញ្ញត្តិ ១

**វិការរូប ៣ គឺ**

រូបស្សលហុតា១ រូបស្សមុទុតា១ រូបស្សកម្មញ្ញតា១

**លក្ខណះរូប ៤ គឺ**

រូបស្សឧបច្ចយោ១ រូបស្សសន្តតិ១ រូបស្សជរតា ១

រូបស្សអនិច្ចតា ១

រូប២៨និងលក្ខណៈមានសេចក្តីប្រែក្នុងគោលធមិមធ្យមវិបស្សនា។ (ដកពីគម្ពីរអភិធម្មត្ថសង្គហៈ)

**ការបែងចែករូបខាងក្នុងនិងខាងក្រៅ ជាដើម**

**មានដូចតទៅ :**

-**អតីតរូប** គឺរូបដែលកន្លងទៅហើយ

-**អនាគតរូប** គឺរូបដែលមិនទាន់មកដល់

-**បច្ចុប្បន្នរូប** គឺរូបដែលកំពុងប្រាកដ។

រូបអតីតក្តី, រូបអនាគតក្តី, បច្ចុប្បន្នក្តី គឺ ព្រះយោគី គប្បីដឹងដោយអំណាចនៃធម៌៤ គឺ

**១-អទ្ធា** គឺកាល

**២-សន្តតិ** គឺតំណ,

**៣-សមយៈ** គឺសម័យ,

**៤-ខណៈ** គឺខណៈ ។

**អជ្ឈត្តិករូប និង ពហិទ្ធារូប**

**បសាទរូប៥** ហៅថា **អជ្ឈត្តិករូប** នៅសល់ **រូប២៣** ហៅថា **ពហិទ្ធារូប ។**

ម្យ៉ាងទៀត **រូប** ដែលមានព្ធដ៏ខាងក្នុង ដ៏ទៀង ហៅថា **អជ្ឈត្តិករូប** រូបដែលមានក្នុងបុគ្គលដទៃ ហៅថា **ពហិទ្ធារូប** ។

## ឱឡារិករូប និង សុខុមរូប

**ឱឡារិករូប** រូបគ្រោតគ្រាតបានដល់ **រូប ១២** គឺ បសាទរូប៥ គោចររូប៤, បឋវីធាតុ ១ តេជោធាតុ១, វាយោធាតុ១, នៅសល់ **រូប១៦** ហៅថា **សុខុមរូប** ។

## ហីនរូប និង បណីតរូប

**-ហីនរូប** រូបអន់ថយ **បណីតរូប** រូបប្រសើរ ការបែងចែកហីនរូប និង បណីតរូបមានការបែងចែក ដោយប្រការ ២ គឺ **បរិយាយ១ និប្បរិយាយ១**

១-ការបែងចែក ដោយបរិយាយនោះគឺលោក បែងចែករូបទៅតាមលំដាប់រូប ដែលមានក្នុងភពខ្ពស់ ទាបដូចបែងចែកថា ៈរូបរបស់ **សុទស្សីព្រហ្ម** អន់ថយ ជាងរូប **អកនិដ្ឋកាព្រហ្ម** តែរូបនេះប្រណិតជាងរូប

**សុទស្សាព្រហ្ម** ប៉ុណ្ណោះជាដើម ។

២-ការបែងចែក **រូបហីនៈ បណីត** ដោយ **និប្បរិយាយ** លោកបែងចែកថាៈ **អកុសលវិបាក** កើតក្នុងរូបណា រូបនោះហៅថា **ហីនរូប, កុសលវិបាក** កើតក្នុងរូបណា រូបនោះហៅថា **បណីតរូប** ។

**ទូរេរូប និង សន្តិកេរូប**

**ទូរេរូប** គឺរូបឆ្ងាយ បានដល់ **សុខុមរូប១៦** នោះឯង ។ **សន្តិកេរូប** គឺរូបជិត បានដល់ **ឱឡារិករូប១២** ។ ន័យម្យ៉ាងទៀតថា ភាពនៃរូបឆ្ងាយនិងជិត ព្រះយោគីគប្បីជ្រាបដោយការប្រកាន់យកក្នុងរូបដោយឱកាស ។

(ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ៣)

## **ទ្វារ ៦ គឺ**

**១-ចក្ខុទ្វារ** មានន័យថា ទ្វារភ្នែកសំដៅយក**ចក្ខុបសាទ**

**២-សោតទ្វារ** មានន័យថា ទ្វារត្រចៀក សំដៅយក **សោតបសាទ**។

**៣-ឃានទ្វារ** មានន័យថា ទ្វារច្រមុះ សំដៅយក **ឃានបសាទ** ។

**៤-ជិវ្ហាទ្វារ** មានន័យថា ទ្វារអណ្តាត សំដៅយក **ជិវ្ហាបសាទ** ។

**៥-កាយទ្វារ** មានន័យថា ទ្វារកាយ សំដៅយក **កាយបសាទ** ។

**៦-មនោទ្វារ** មានន័យថា ទ្វារចិត្ត សំដៅយក **ភវង្គៈ**។

## អារម្មណ៍ ៦ គឺ

**១-រូបារម្មណ៍** = អារម្មណ៍គឺ រូប បានដល់ វណ្ណរូប មានរូបពណ៌ខៀវ លឿងជាដើម ។

**២-សទ្ទារម្មណ៍** = អារម្មណ៍គឺ សំឡេង មានសំឡេងស្គរជាដើម ។

**៣-គន្ធារម្មណ៍** = អារម្មណ៍គឺ ក្លិន មានក្លិនរបស់មើមឈើជាដើម ។

**៤-រសារម្មណ៍** = អារម្មណ៍គឺរស មានរសជាតិរបស់មើម ឬដើមឈើជាដើម ។

**៥-ផោដ្ឋព្វារម្មណ៍** = អារម្មណ៍គឺ ផោដ្ឋព្វៈ បានដល់ធាតុ៣គឺ បឋវីធាតុ១ តេជោធាតុ១ វាយោធាតុ១ ។

**៦-ធម្មារម្មណ៍** = អារម្មណ៍គឺធម៌ បានដល់ធម៌ ៦ គឺ បសាទរូប ១, សុខុមរូប ១, ចិត្ត ១, ចេតសិក ១, និព្វាន ១, បញ្ញត្តិ ១, ។

**ចិត្ត និង ចេតសិក កើតតាមទ្វារ៦ គឺ**

**១-ចិត្ត** និង **ចេតសិក** កើតតាម ចក្ខុទ្វារ ។

**២- ចិត្ត** និង **ចេតសិក** កើតតាម សោតទ្វារ ។

**៣- ចិត្ត** និង **ចេតសិក** កើតតាម ឃានទ្វារ ។

**៤- ចិត្ត** និង **ចេតសិក** កើតតាម ជិវ្ហាទ្វារ ។

**៥- ចិត្ត** និង **ចេតសិក** កើតតាម កាយទ្វារ ។

**៦- ចិត្ត** និង **ចេតសិក** កើតតាម មនោទ្វារ ។

**អារម្មណ៍របស់ចិត្តនិងចេតសិកតាមទ្វារ៦គឺ**

**- រូបារម្មណ៍** នឹងបានមកជាអារម្មណ៍របស់ចិត្ត និង

ចេតសិកដែលកើតតាមទ្វារ២ គឺចក្ខុទ្វារ១ មនោទ្វារ១

- **សទ្ទារម្មណ៍** នឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិកដែលកើតតាមទ្វារ២ គឺសោតទ្វារ មនោទ្វារ១

- **គន្ធារម្មណ៍** នឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិកដែលកើតតាមទ្វារ២គឺឃានទ្វារ១មនោទ្វារ១

- **រសារម្មណ៍** នឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិកដែលកើតតាមទ្វារ២ គឺជិវ្ហាទ្វារ១ មនោទ្វារ១

-**ផោដ្ឋព្វារម្មណ៍** នឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិកដែលកើតតាមទ្វារ២គឺកាយទ្វារ១មនោទ្វារ១

- **ធម្មារម្មណ៍** នឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិកដែលកើតតាមមនោទ្វារតែម្យ៉ាង។

ចិត្តនិងចេតសិក ដែលកើតតាមទ្វារទាំង ៦នោះ ហៅ

ថាធ**ម្មារម្មណ៍**មែនពិត ។

ចិត្ត និងចេតសិកដែលកើតតាម **បញ្ចទ្វារ** មាន **ចក្ខុទ្វារ**ជាដើមអាចកំណត់ដឹងនូវអារម្មណ៍មួយៗ តាមទ្វារក្នុងបច្ចុប្បន្នបាន មិនអាចកំណត់ដឹងនូវអារម្មណ៍ក្នុងអតីត និងអនាគតបានឡើយ ។

ឯចិត្តនិងចេតសិកដែលកើតតាម **មនោទ្វារ** វិញ អាចកំណត់ដឹងនូវអារម្មណ៍៦គ្រប់ទ្វារទាំងអស់ ក្នុងបច្ចុប្បន្ន ក្នុងអតីត និងអនាគតបាន ។

ចិត្តនិងចេតសិកដែលកើតតាមទ្វារទាំង៦ បានដល់ធម៌៥ គឺ **វិញ្ញាណ១, ផស្ស១, វេទនា១, សញ្ញា១, ចេតនា១**, ធម៌ទាំង៥នេះហៅថាពួក ធម៌មាន **ផស្សៈ** ជាគម្រប់៥ក៏បាន ។

សេចក្ដីប្រែ និង លក្ខណៈនៃធម៌ទាំង៥នេះ មានពោលទុកក្នុងគោលធម៌ថ្នាក់មធ្យមវិបស្សនាហើយ ។

## ការកំណត់ដឹងនូវនាមនិងរូបតាមទ្វារ៦

- **រូប** ដែលមកប៉ះផ្ទប់ នឹង ចក្ខុទ្វារនោះកំណត់[១] ជា **រូបធម៌**។ ពួកធម៌[២] មានផស្សៈ ជាគម្រប់៥ ដែលកំណត់ដឹងនូវរូបនោះ ជា **នាមធម៌** ។
- **សំឡេង** ដែលមកប៉ះផ្ទប់នឹងសោតទ្វារនោះ កំណត់ជា **រូបធម៌** ពួកធម៌មានផស្សៈជាគម្រប់៥ ដែលកំណត់ដឹងនូវសំឡេងនោះ ជា **នាមធម៌** ។

---

[១] បញ្ញាជាអ្នកកំណត់ដឹង ។

[២] ពួកធម៌មានផស្សៈជាគម្រប់ ៥ ដែលកំណត់ដឹងនូវអារម្មណ៍នោះតែងតែកើតឡើងដោយអំណាចនៃបញ្ញា ។

- **ក្លិន** ដែលមកប៉ះផ្ទប់នឹងឃានទ្វារនោះ កំណត់ជា **រូបធម៌** ពួកធម៌មានផស្សៈ ជាគម្រប់៥ ដែលកំណត់ដឹងនូវរសនោះ ជា **នាមធម៌** ។

- **រស** ដែលមកប៉ះផ្ទប់នឹងជិវ្ហាទ្វារនោះ កំណត់ជា **រូបធម៌** ពួកធម៌មានផស្សៈជាគម្រប់៥ ដែលកំណត់ដឹងនូវក្លិននោះជា **នាមធម៌**។

- **ផោដ្ឋព្វៈ** ដែលមកប៉ះផ្ទប់នឹងកាយទ្វារនោះ កំណត់ជា **រូបធម៌** ពួកធម៌មានផស្សៈជាគម្រប់៥ ដែលកំណត់ដឹងនូវផោដ្ឋព្វនោះ ជា **នាមធម៌** ។

- **ធម៌** គឺបសាទរូប៥, សុខុមរូប១៦, ដែលមកប្រាកដដល់ចិត្តនោះ កំណត់ថាជា **រូបធម៌**។ ពួកធម៌មានផស្សៈជាគម្រប់៥ ដែលកំណត់ដឹងនូវរូប

នោះ ជា **នាមធម៌** ។

ក្នុងការកំណត់ដឹងនូវនាមរូបក្នុងវិបស្សនានេះ ព្រះយោគីត្រូវកំណត់នូវ **រូបធម៌** ឱ្យឃើញច្បាស់ប្រាកដមុន ទើបបានកំណត់ដឹងនូវ **នាមធម៌** ក្រោយ ព្រះយោគីត្រូវកំណត់ដឹង ពិចារណាឱ្យឃើញថា៖ អត្តភាពក្នុងបច្ចុប្បន្ននេះក្តី, អតីតក្តី, អនាគតក្តីជាដើម មានត្រឹមតែនាមរូបប៉ុណ្ណោះ មិនមែនសត្វ បុគ្គល មនុស្ស ទេវតា ជាដើមឡើយ ។

**ការសង្រ្គោះពួកធម៌មានផស្សៈគម្រប់៥ ចូលក្នុងខន្ធ៥**

**-វេទនា** ធម្មជាតិ សោយនូវអារម្មណ៍សង្រ្គោះចូលក្នុង **វេទនាក្ខន្ធ** ។

**-សញ្ញា** ធម្មជាតិចាំនូវអារម្មណ៍ សង្រ្គោះចូល

ក្នុង **សញ្ញាខន្ធ** ។

**-ផស្សៈ** ធម្មជាតិប៉ះនូវអារម្មណ៍១

**-ចេតនា** ធម្មជាតិសន្សំនូវអារម្មណ៍១ ទាំង២នេះ សង្គ្រោះចូលក្នុង **សង្ខារក្ខន្ធ** ។

**-វិញ្ញាណ** ធម្មជាតិដឹងនូវអារម្មណ៍សង្គ្រោះ ចូលក្នុង **វិញ្ញាណក្ខន្ធ** ។

(ដកស្រង់ពីគម្ពីរវិសុទ្ធិមគ្គភាគ៣)

## ខ - សិក្សាអំពីអារម្មណ៍របស់វិបស្សនាបន្ត

អារម្មណ៍របស់វិបស្សនាទាំងអស់មាន៧៣ គឺ ខន្ធ៥, អាយតនៈ១២, ធាតុ១៨, ឥន្ទ្រិយ២២, សច្ច៤, បដិច្ចសមុប្បាទ១២ ។

## ខន្ធ ៥ គឺ

**១-រូបក្ខន្ធ** ក្រុមរូប,

**២-វេទនាខន្ធ** ក្រុមវេទនា,

**៣-សញ្ញាខន្ធ** ក្រុមសញ្ញា,

**៤-សង្ខារក្ខន្ធ** ក្រុមសង្ខារ,

**៥-វិញ្ញាណក្ខន្ធ** ក្រុមវិញ្ញាណ។

គប្បីពិចារណាឱ្យឃើញថា មានត្រឹមតែខន្ធប៉ុណ្ណោះ មិនមែនសត្វ, បុគ្គល, មនុស្ស, ទេវតាជាដើម។

## អាយតនៈ ១២គឺ

**១-ចក្ខាយតនៈ** អាយតនៈ គឺភ្នែក,

**២-រូបាយតនៈ** អាយតនៈ គឺរូប,

**៣-សោតាយតនៈ** អាយតនៈ គឺត្រចៀក,

**៤-សទ្ទាយតនៈ** អាយតនៈ គឺសំឡេង,

**៥-ឃានាយតនៈ** អាយតនៈ គឺច្រមុះ,

**៦-គន្ធាយតនៈ** អាយតនៈ គឺក្លិន,

**៧-ជិវ្ហាយតនៈ** អាយតនៈ គឺអណ្តាត,

**៨-រសាយតនៈ** អាយតនៈ គឺរស,

**៩-កាយាយតនៈ** អាយតនៈ គឺកាយ,

**១០-ផោដ្ឋព្វាយតនៈ** អាយតនៈ គឺផោដ្ឋព្វៈ,

**១១-មនាយតនៈ** អាយតនៈ គឺចិត្ត,

**១២-ធម្មាយតនៈ** អាយតនៈ គឺធមិ,

គប្បីពិចារណាឱ្យឃើញថា មានត្រឹមតែអាយតនៈ ១២ប៉ុណ្ណោះ មិនមែនសត្វ បុគ្គល មនុស្ស ទេវតា ជាដើម ។

## ធាតុ ១៨ គឺ

១-**ចក្ខុធាតុ** ធាតុ គឺភ្នែក,

២-**រូបធាតុ** ធាតុ គឺរូប,

៣-**ចក្ខុវិញ្ញាណធាតុ** ធាតុ គឺចក្ខុវិញ្ញាណ,

៤-**សោតធាតុ** ធាតុ គឺត្រចៀក,

៥-**សទ្ទធាតុ** ធាតុ គឺសំឡេង,

៦-**សោតវិញ្ញាណធាតុ** ធាតុ គឺសោតវិញ្ញាណ,

៧-**ឃានធាតុ** ធាតុ គឺច្រមុះ,

៨-**គន្ធធាតុ** ធាតុ គឺក្លិន,

៩-**ឃានវិញ្ញាណធាតុ** ធាតុ គឺឃានវិញ្ញាណ,

១០-**ជិវ្ហាធាតុ** ធាតុ គឺអណ្តាត,

១១-**រសធាតុ** ធាតុ គឺរស,

**១២-ជិវ្ហាវិញ្ញាណធាតុ** ធាតុ គឺជិវ្ហាវិញ្ញាណ,

**១៣-កាយធាតុ** ធាតុ គឺកាយ,

**១៤-ផោដ្ឋព្វធាតុ** ធាតុ គឺផោដ្ឋព្វៈ,

**១៥-កាយវិញ្ញាណធាតុ** ធាតុ គឺកាយវិញ្ញាណ,

**១៦-មនោធាតុ** ធាតុ គឺចិត្ត,

**១៧-ធម្មធាតុ** ធាតុ គឺធម៌,

**១៨-មនោវិញ្ញាណធាតុ** ធាតុ គឺមនោវិញ្ញាណ។

គប្បីពិចារណាឱ្យឃើញថា មានត្រឹមតែធាតុ ១៨ប៉ុណ្ណោះ មិនមែនសត្វ បុគ្គល មនុស្ស ទេវតា ជាដើម។

## ឥន្ទ្រិយ ២២

**ឥន្ទ្រិយ**មានន័យថា **ភារៈ**ជាធំ ឥស្សរភាព អានុភាព ជាដើមមាន ២២ គឺ

**១-ចក្ខុន្ទ្រិយ** ឥន្ទ្រិយ គឺភ្នែក,

**២-សោតិន្ទ្រិយ** ឥន្ទ្រិយ គឺត្រចៀក,

**៣-ឃានិន្ទ្រិយ** ឥន្ទ្រិយ គឺច្រមុះ,

**៤-ជិវ្ហិន្ទ្រិយ** ឥន្ទ្រិយ គឺអណ្ដាត,

**៥-កាយិន្ទ្រិយ** ឥន្ទ្រិយ គឺកាយ,

**៦-មនិន្ទ្រិយ** ឥន្ទ្រិយ គឺចិត្ត,

**៧-ឥត្ថិន្ទ្រិយ** ឥន្ទ្រិយ គឺភេទស្រី,

**៨-បុរិសិន្ទ្រិយ** ឥន្ទ្រិយ គឺភេទបុរស,

**៩-ជីវិតិន្ទ្រិយ** ឥន្ទ្រិយ គឺការរស់នៅ,

**១០-សុខិន្ទ្រិយ** ឥន្ទ្រិយ គឺសេចក្ដីសុខ,

**១១-ទុក្ខិន្ទ្រិយ** ឥន្ទ្រិយ គឺសេចក្ដីទុក្ខ,

**១២-សោមនស្សិន្ទ្រិយ** ឥន្ទ្រិយ គឺភាពនៃចិត្តល្អ,

**១៣-ទោមនស្សិន្ទ្រិយ** ឥន្ទ្រិយ គឺភាពនៃចិត្តអាក្រក់,

**១៤-ឧបេក្ខិន្ទ្រិយ** ឥន្ទ្រិយ គឺវេទនាមិនមែនសុខ មិនមែនទុក្ខ បានដល់ការសោយអារម្មណ៍កណ្តាលៗ,

**១៥-សទ្ធិន្ទ្រិយ** ឥន្ទ្រិយ គឺសទ្ធា,

**១៦-វីរិយិន្ទ្រិយ** ឥន្ទ្រិយ គឺវីរិយ,

**១៧-សតិន្ទ្រិយ** ឥន្ទ្រិយ គឺសតិ,

**១៨-សមាធិន្ទ្រិយ** ឥន្ទ្រិយ គឺសមាធិ,

**១៩-បញ្ញិន្ទ្រិយ** ឥន្ទ្រិយ គឺបញ្ញា,

**២០-អនញ្ញតញ្ញស្សាមីតិន្ទ្រិយ** សំដៅយកសោតាបត្តិ-មគ្គ ឥន្ទ្រិយគឺសោតាបត្តិមគ្គញ្ញាណ

**២១-អញ្ញិន្ទ្រិយ** សំដៅយកឥន្ទ្រិយគឺសោតាបត្តិផល-ញ្ញាណរហូតដល់អរហត្តមគ្គញ្ញាណ,

**២២-អញ្ញាតាវិន្ទ្រិយ** សំដៅយកឥន្ទ្រិយគឺអរហត្តផល-ញ្ញាណ។ អារម្មណ៍២២នេះបានជាហៅថា**ឥន្ទ្រិយ** ព្រោះមានភាពជាធំ មានតួនាទីធំដោយឡែកៗពីគ្នា ក្នុងការទទួលយកនូវអារម្មណ៍។

គប្បីពិចារណាឱ្យឃើញថា មានត្រឹមតែជាសភាពធំដោយឡែកៗប៉ុណ្ណោះ មិនមែនសត្វ បុគ្គល មនុស្សទេវតា ជាដើម។

## សច្ចៈ ៤

**សច្ចៈ** មានន័យថាធម៌ពិតមាន ៤យ៉ាងគឺ : ទុក្ខសច្ចៈ១, សមុទយសច្ចៈ១, និរោធសច្ចៈ១ មគ្គសច្ចៈ១ ។

**-ទុក្ខសច្ចៈ** សេចក្តីលំបាកជាធម៌ពិត បានដល់ទុក្ខ១២

កង មានជាតិទុក្ខជាដើម ។

**-សមុទយសច្ចៈ** ហេតុដែលនាំឱ្យកើតទុក្ខលំបាក ជាធម៌ពិតបានដល់តណ្ហា៣ ឬ តណ្ហា១០៨ មានកាមតណ្ហា ជាដើម ។

**-និរោធសច្ចៈ** ធម៌សម្រាប់រំលត់ទុក្ខជាធម៌ពិត មានគុណថា កិរិយារលត់បង់នូវតណ្ហាមិនមានសេសសល់ជាដើម ។

**-មគ្គសច្ចៈ** ផ្លូវឧបាយសម្រាប់រំលត់ទុក្ខជាធម៌ពិត មានអង្គ៨ មានសម្មាទិដ្ឋិជាដើម ។

**កិច្ចក្នុងសច្ចៈមាន ៤ យ៉ាងគឺ**

**១-បរិញ្ញា** ការកំណត់ដឹងនូវទុក្ខសច្ចៈ,

**២-បហាន** ការលះបង់នូវសមុទយសច្ចៈ,

**៣-សច្ឆិករណ** ការធ្វើឱ្យជាក់ច្បាស់នូវនិរោធសច្ចៈ

**៤-ភាវនា** ការចម្រើននូវមគ្គសច្ចៈ ។

**ភាពសូន្យក្នុងសច្ចៈ ៤ យ៉ាងគឺ**

**១-ន វេទកោ** មិនមានអ្នកសោយ,

**២-ន ការកោ** មិនមានអ្នកកសាង,

**៣-ន និព្វុតោ** មិនមានអ្នករំលត់,

**៤-ន គមកោ** មិនមានអ្នកធ្វើដំណើរទៅ, គប្បីពិចារណាឱ្យឃើញត្រឹមតែធម៌ប៉ុណ្ណោះមិនមែនសត្វ បុគ្គល មនុស្ស ទេវតា ជាដើម ។

**បដិច្ចសមុប្បាទ ១២**

**បដិច្ចសមុប្បាទ** គឺបណ្ឌិតគប្បីជ្រាបថា **បច្ចយធម្មោ** ធម៌ជាតួបច្ច័យហ្នឹងឯង ហៅថា **បដិច្ចសមុប្បាទ** មាន

១២ អង្គគឺ

**១-អវិជ្ជា** សេចក្ដីមិនដឹង,

**២-សង្ខារ** ធម្មជាតិតាក់តែងនូវសង្ខតធម៌,

**៣-វិញ្ញាណ** ធម្មជាតិដឹងនូវអារម្មណ៍,

**៤-នាមរូប** នាម ធម្មជាតិឱនទៅកាន់អារម្មណ៍

រូបធម្មជាតិបែកធ្លាយ,

**៥-អាយតនៈ** (ទី)ជាទីត ជាទីនៅ ជាទីកើត ជាអណ្ដូង,

**៦-ផស្សៈ** ធម្មជាតិប៉ះ,

**៧-វេទនា** ធម្មជាតិសោយនូវអារម្មណ៍,

**៨-តណ្ហា** ធម្មជាតិតក់ស្លុតដោយជុំវិញ,

**៩-ឧបាទាន** ធម្មជាតិ ប្រកាន់មាំ,

**១០-ភព** ភព,

**១១-ជាតិ** ការកើត,

**១២-ជរាមរណៈ** ការចាស់គ្រាំគ្រា និងសេចក្ដីស្លាប់។

គប្បីសិក្សាឱ្យឃើញច្បាស់ថា ធមិទាំងឡាយ សុទ្ធតែកើតឡើងអំពីបច្ច័យកើតត ៗគ្នាជាលំដាប់មិនមែន សត្វ បុគ្គល មនុស្ស ទេវតាជាដើមឡើយ។

(ដកពីគម្ពីរវិសុទ្ធមគ្គភាគ ៣)

## VII- ការកំណត់ដឹងនូវហេតុបច្ច័យរបស់នាមរូបបញ្ចក្ខន្ធដែលប្រព្រឹត្តនៅក្នុងភព៣ កាល៣

- ការសិក្សាអំពីហេតុបច្ច័យរបស់នាមរូប ខន្ធ៥នោះ មានច្រើនបែប ច្រើនយ៉ាងដូចតទៅ :

### ហេតុបច្ច័យរបស់នាមរូប

ព្រះយោគីអង្គខ្លះ លោកពិចារណាដូចខាងក្រោមនេះ

- ធម៌៥យ៉ាងគឺ **អវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១ អាហារ១,** ជាហេតុបច្ច័យរបស់ **រូប** ។ **អវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១,** ៤នេះ ជាតួហេតុ, **អាហារ១** ជាតួបច្ច័យ ។

**នាមធម៌** មាន ៦យ៉ាង គឺ **ចក្ខុវិញ្ញាណ១, សោតវិញ្ញាណ១, ឃានវិញ្ញាណ១, ជិវ្ហាវិញ្ញាណ១, កាយវិញ្ញាណ១, មនោវិញ្ញាណ១** ។

វិញ្ញាណ៦នេះ តែងកើតឡើងព្រោះអាស្រ័យ អារម្មណ៍៦ មកប៉ះផ្ទប់នឹងទ្វារ៦ ដូចចក្ខុវិញ្ញាណកើតឡើងព្រោះអាស្រ័យចក្ខុផង រូបផងជាដើម ។

**បច្ច័យរបស់នាមរូបដទៃទៀត**

ព្រះយោគីអង្គខ្លះ លោកពិចារណាដូចខាងក្រោមនេះ

- បច្ច័យរបស់នាមមាន ២យ៉ាងគឺ

**សាធារណបច្ច័យ១ អសាធារណបច្ច័យ១**

**-បច្ច័យ** របស់រូបមាន ៤យ៉ាងគឺ កម្ម១ ចិត្ត១ ឧតុ១ អាហារ១

## បច្ច័យរបស់នាមរូបដទៃទៀត

បច្ច័យរបស់ **នាមរូប** គឺព្រះយោគីអង្គខ្លះលោកពិចារណាទៅតាម **បដិច្ចសមុប្បាទ** មានអង្គ ១២ ជា**បដិលោម** មានការពិចារណាថា កាលដែលជាតិមាន ទើបជរាមរណៈរបស់សង្ខារមាន ជាដើម ។

## បច្ច័យរបស់នាមរូបដទៃទៀត

ព្រះយោគីអង្គខ្លះ ពិចារណាបច្ច័យរបស់ **នាមរូប** ដោយអំណាចនៃ **កម្មវដ្ដ** និង **វិបាកវដ្ដ** ។

**កម្មវដ្ត** មានធម៌៥ គឺ អវិជ្ជា១, សង្ខារ១, តណ្ហា១, ឧបាទាន១, ភព១ ។

**វិបាកវដ្ត** មានធម៌៥ គឺ វិញ្ញាណ១, នាមរូប១ អាយតនៈ១, ផស្សៈ១, វេទនា១ ។

## បច្ច័យរបស់នាមរូបដទៃទៀត

បច្ច័យរបស់ **នាមរូប** គឺព្រះយោគីអង្គខ្លះ លោកលើកឡើងនូវកម្ម១២ប្រការ ដាក់ក្នុង**កម្មវដ្ត** ហើយពិចារណាកំណត់បច្ច័យរបស់ **នាមរូប** ដោយអំណាច **កម្មវដ្ត** និង **វិបាកវដ្ត** ។

កម្មមាន១២ប្រការនោះ ចែកជា៣ពួកដូចខាងក្រោមនេះគឺ

## ពួកទី១ ឱ្យផលតាមសម័យ

**១-ទិដ្ឋធម្មវេទនីយកម្ម** កម្មឱ្យផលក្នុងភពនេះ

**២-ឧបបជ្ជវេទនីយកម្ម**កម្មឱ្យផលក្នុងកាលកើតហើយក្នុងភពមុខ

**៣-អបរាបរិយវេទនីយកម្ម**កម្មឱ្យផលក្នុងភពតៗទៅ

**៤-អហោសិកម្ម** កម្មឱ្យផលសម្រេចហើយ

## ពួកទី ២ ឱ្យផលតាមកិច្ច

**១-ជនកកម្ម** កម្មតាក់តែងឱ្យកើត

**២-ឧបត្ថម្ភកកម្ម** កម្មជ្រោមជ្រែង

**៣-ឧបបីឡកកម្ម** កម្មបៀតបៀន

**៤-ឧបឃាតកម្ម** កម្មផ្តាច់បង់

## ពួកទី ៣ ឱ្យផលតាមលំដាប់

**១-គរុកម្ម** កម្មធ្ងន់

**២-ពហុលកម្ម** កម្មមានចំនួនច្រើនគឺកម្មសន្សំ

**៣-អាសន្នកម្ម** កម្មកាលជិតនឹងស្លាប់គឺកម្មដែលនឹកឃើញក្នុងពេលជិតស្លាប់ ។

**៤-កតត្តាវាបនកម្ម** កម្មគ្រាន់តែធ្វើគឺកម្មដែលផុតស្រឡះចាកកម្មទាំង៣នោះ មានការសេពច្រើនបានហើយ រឿយៗ ។

### ហេតុបច្ច័យរបស់ខន្ធ ៥

ហេតុបច្ច័យរបស់ រូបខន្ធ មាន៥ គឺអវិជ្ជា១ តណ្ហា១, ឧបាទាន១, កម្ម១, អាហារ១ ។

ហេតុបច្ច័យរបស់ **វេទនាខន្ធ១, សញ្ញាខន្ធ១ សង្ខារក្ខន្ធ១**, មាន៥ គឺ អវិជ្ជា១, តណ្ហា១ ឧបាទាន១, កម្ម១, ផស្សៈ១ ។

ហេតុបច្ច័យរបស់ **វិញ្ញាណខន្ធ** មាន៥ គឺ : អវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១, នាមរូប១ ។

**នាមរូប** ក្នុងអតីតក្តី បច្ចុប្បន្នក្តី និងក្នុងអនាគតក្តី ដែលកើតតគ្នារកទីបំផុតគ្មាន ក៏ព្រោះតែហេតុបច្ច័យនៅមាន កាលដែលហេតុបច្ច័យរលត់ហើយ នាមរូបនោះក៏រលត់ដែរ ។

កាលបើព្រះយោគីបានកំណត់ដឹងច្បាស់នូវហេតុបច្ច័យរបស់ **នាមរូប** ឬ **ខន្ធ៥** បានជាក់ ច្បាស់លាស់ព្រះយោគីនោះ ក៏រួចចាកសេចក្តីសង្ស័យ ១៦ យ៉ាងមែនពិត ។

**សេចក្តីសង្ស័យ ១៦ នោះគឺ**

អតីត ៥ , បច្ចុប្បន្ន ៦ , អនាគត ៥

( ដកពីគម្ពីរវិសុទ្ធមគ្គ ៣)

## VIII- ការប្រតិបត្តិឃើញព្រះត្រៃលក្ខណ៍ ដោយអំណាចកលាបសម្មសនញ្ញាណ និងឧទយព្វយានុបស្សនាញាណ

## កលាបសម្មសនញ្ញាណ

កលាបសម្មសនញ្ញាណ មានន័យថា ប្រាជ្ញាដែលពិចារណាធម៌ជាពួកៗ ។

### ពួកធម៌ដែលជាអារម្មណ៍ក្នុងវិបស្សនា មាន២៥ពួក គឺ

-**ខន្ធ** ៥ មាន រូបក្ខន្ធ ជាដើម ។

-**ទ្វារ** ៦ មាន ចក្ខុទ្វារ ជាដើម ។

-**អារម្មណ៍** ៦ មាន រូបារម្មណ៍ ជាដើម ។

-**វិញ្ញាណ** ៦ មាន ចក្ខុវិញ្ញាណ ជាដើម ។

-**ផស្សៈ** ៦ មាន ចក្ខុសម្ផស្ស ជាដើម ។

-**វេទនា** ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម ។

-**សញ្ញា** ៦ មានរូបសញ្ញា ជាដើម ។

-**ចេតនា** ៦ មានរូបសញ្ចេតនា ជាដើម ។

-**តណ្ហា** ៦ មានរូបតណ្ហា ជាដើម ។

-**វិតក្កៈ** ៦ មានរូបវិតក្កៈ ជាដើម ។

-**វិចារៈ** ៦ មានរូបវិចារៈ ជាដើម ។

-**ធាតុ** ៦ មានបឋវីធាតុ ជាដើម ។

-**កសិណ** ១០ មានបឋវីកសិណ ជាដើម ។

-**កោដ្ឋាសៈ** ៣២មានកេសា ជាដើម ។

-**អាយតនៈ** ១២ មានចក្ខាយតនៈ ជាដើម ។

-**ធាតុ** ១៨ មានចក្ខុធាតុ ជាដើម ។

**-ឥន្ទ្រិយ** ២២ មានចក្ខុន្ទ្រិយ ជាដើម ។

**-ធាតុ** ៣ មានកាមធាតុ ជាដើម ។

**-ភព** ៣ មានកាមភព ជាដើម ។

**-ភព** ៣ មានទៀត មានសញ្ញាភព ជាដើម ។

**-ភព** ៣ មានទៀត ឯកវោការភព ជាដើម ។

**-ឈាន** ៤មានបឋមជ្ឈាន ជាដើម ។

**-អប្បមញ្ញា** ៤ មានមេត្តាចេតោវិមុត្តិជាដើម ។

**-សមាបត្តិ** ៤ មានអាកាសានញ្ចាយតនៈជាដើម ។

**-អង្គបដិច្ចសមុប្បាទ** ១២មានអវិជ្ជា ជាដើម ។

ពួកលោកុត្តរធម៌ មិនមានដល់ការពិចារណានៃព្រះយោគីជាបុថុជ្ជន ព្រោះមិនទាន់បានត្រាស់ដឹង ។

ព្រះយោគី គប្បីពិចារណានូវអង្គនៃធម៌ណាដែលមកប្រាកដដល់ចិត្តរឿយៗ ឱ្យគ្រប់ឥរិយាបថ ។

## លក្ខណៈ ៣

**១-អនិច្ចំ** មិនទៀង ក្នុងខន្ធ ៥ មាន ៥៥។

**២-ទុក្ខំ** ជាទុក្ខ ក្នុងខន្ធ៥ មាន ៥៥។

**៣-អនត្តា** មិនមែនខ្លួន មិនមែនជារបស់ខ្លួន ក្នុងខន្ធ៥ មាន ៥៥។

ការធ្វើឱ្យ **អនិច្ច ទុក្ខ អនត្តា សម្មសនញ្ញាណ** រឹងមាំគឺ គប្បីពិចារណានូវខន្ធ៥ ខន្ធនីមួយៗដោយអាការ៤០ទៀត

## អាការ ៤០ នោះគឺ

**១-អនិច្ចតោ** មិនទៀង

**២-ទុក្ខតោ** ជាទុក្ខ

**៣-រោគតោ** ជារោគ

**៤-គណ្ឋតោ** ជាបូស

**៥-សល្លតោ** ជាសរ

**៦-អឃតោ** ជាទុក្ខលំបាក

**៧-អាពាធតោ** ជាជំងឺដង្កាត់

**៨-បរតោ** ជារបស់អ្នកដទៃ

**៩-បលោកតោ** ជាធម្មជាតិឆេះទ្រោល

**១០-ឦតិតោ** ជាចង្រៃ

**១១-ឧបទ្ទវតោ** ជាធម្មជាតិមិននាំមកនូវសេចក្តី ចម្រើន

**១២-ភយតោ** ជាភ័យ

**១៣-ឧបសគ្គតោ** ជាគ្រឿងរារាំង

**១៤-ចលតោ** កម្រើកញាប់ញ័រ

**១៥-បភង្គុតោ** ពុកផុយ

**១៦-អទ្ធុវតោ** មិនទៀង

**១៧-អត្តាណតោ** មិនមានទីពឹងអាស្រ័យ

**១៨-អលេណតោ** មិនមានទីពួន

**១៩-អសរណតោ** មិនមានទីពឹង

**២០-រិត្តតោ** មានប្រមាណតិច

**២១-តុច្ឆតោ** ជាធម្មជាតិទទេ

**២២-សុញ្ញតោ** ជាធម្មជាតិសូន្យ

**២៣-អនត្តតោ** មិនមែនខ្លួន

**២៤-អាទីនវតោ** ជាទោស

**២៥-វិបរិណាមធម្មតោ** មានការប្រែប្រួលជា ធម្មតា

**២៦-អសារកតោ** មិនមានខ្លឹមសារ

**២៧-អឃមូលតោ** ជាឫសគល់នៃសេចក្តីទុក្ខ លំបាក

**២៨-វធកតោ** ជាអ្នកសម្លាប់

**២៩-វិភវតោ** វិនាស ( មិនចម្រើន)

**៣០-សាសវតោ** ប្រកបដោយអាសវៈ

**៣១-សង្ខតតោ** មានបច្ច័យប្រជុំតាក់តែង

**៣២-មារាមិសតោ** ជាចំណីរបស់មារ

**៣៣-ជាតិធម្មតោ** មានការកើតជាធម្មតា

**៣៤-ជរាធម្មតោ** មានការចាស់គ្រាំគ្រាជាធម្មតា

**៣៥-ព្យាធិធម្មតោ** មានការឈឺចាប់ជាធម្មតា

**៣៦-មរណធម្មតោ** មានសេចក្ដីស្លាប់ជាធម្មតា

**៣៧-សោកធម្មតោ** មានសេចក្ដីសោកជាធម្មតា

**៣៨-បរិទេវធម្មតោ** មានការខ្សឹកខ្សួលជាធម្មតា

**៣៩-ឧបាយាសធម្មតោ** មានសេចក្ដីចង្អៀតចង្អល់ទង្គឹះជាធម្មតា

**៤០-សង្កិលេសិកធម្មតោ** ជាធម្មជាតិប្រកបដោយកិលេសជាធម្មតា។

**ការធ្វើសេចក្ដីសង្គ្រោះនូវអាការ៤០ ចូលក្នុងត្រៃលក្ខណ៍**

អាការទាំង៤០នេះ បើសង្គ្រោះចូលក្នុងត្រៃលក្ខណ៍ មានដូចតទៅ ៖

**១-បញ្ចាស អនិច្ចានុបស្សនានិ**

ការពិចារណារឿយៗ (នូវខន្ធ៥) ថាមិនទៀងមាន ៥០ គឺ ក្នុងខន្ធ មួយៗមាន ១០ (១០ x ៥ = ៥០) ។ ក្នុងខន្ធមួយៗមាន ១០ នោះគឺ ៖

អនិច្ចតោ១,បរលោកតោ១,ចលតោ១,បភង្គុតោ១, អទ្ធុវតោ១, វិបរិណាមធម្មតោ១,អសារកតោ១, វិភវតោ១, សង្ខតតោ១, មរណធម្មតោ១ ។

**២-បញ្ចវីសតិអនត្តានុបស្សនានិ** ការពិចារណារឿយៗ (នូវខន្ធ៥) ជាអនត្តាមាន ២៥ គឺ ក្នុងខន្ធ

មួយៗមាន ៥ ( ៥ x ៥= ២៥ ) ។

ក្នុងខន្ធមួយៗមាន៥យ៉ាងនោះគឺ បរតោ១,រិត្តតោ១,តុច្ឆតោ១, សុញ្ញតោ១, អនត្តតោ១ ។

## ៣-បញ្ចវីសតិសតំ ទុក្ខានុបស្សនានិ

ការពិចារណារឿយៗនូវខន្ធ៥ ថាជាទុក្ខ មាន១២៥ គឺ

ក្នុងខន្ធមួយៗមាន ២៥ ( ២៥ x៥=១២៥)

ក្នុងខន្ធមួយៗ មាន២៥នោះ បានដល់ អាការ៤០ ដក អាការ ១០ ក្នុងអនិច្ចំ និង អាការៈ ៥ ក្នុងអនត្តាចេញ នៅសល់២៥ជាអាការក្នុងទុក្ខំ( ៤០( ១០+៥) =២៥) ។

**-រួមសម្មសនញ្ញាណទាំង៣** ត្រូវជា ២០០ ( ៥០ + ១២៥ + ២៥ = ២០០)

## ឧទយព្វយានុបស្សនាញាណ

**ឧទយព្វយានុបស្សនាញាណ** មានន័យថា ប្រាជ្ញាពិចារណាឃើញរឿយៗ នូវកិរិយាកើត និងកិរិយាអស់ទៅនៃពួកធម៌ជាបច្ចុប្បន្ន។

កិរិយាកើតឡើងហៅថា **ឧទយៈ** កិរិយាអស់ទៅហៅថា **វយៈ** ។

គប្បីពិចារណានូវកិរិយាកើត និងកិរិយាអស់ទៅបែកធ្លាយទៅ រលត់ទៅនៃធម៌ មានខន្ធ៥ជាដើមក្នុងបច្ចុប្បន្ន បន្ទាប់មកគប្បីពិចារណាឱ្យឃើញនូវលក្ខណៈ៥កើត និង លក្ខណៈរលត់របស់បញ្ចក្ខន្ធថែមទៀត។

**លក្ខណៈ៥កើត និងលក្ខណៈ៥រលត់ របស់បញ្ចក្ខន្ធ**

**- លក្ខណៈ ៥ កើតនៃរូបក្ខន្ធគឺ**

អវិជ្ជា១, តណ្ហា១, កម្ម១, អាហារ១, និព្វត្តិ-លក្ខណៈ១។

- **លក្ខណៈ៥រលត់នៃរូបក្ខន្ធ** គឺរលត់អវិជ្ជា១, តណ្ហា១, កម្ម១, អាហារ១, វិបរិណាមលក្ខណៈ១។

**លក្ខណៈ៥កើតនៃ វេទនាខន្ធ១, សញ្ញាខន្ធ១, សង្ខារក្ខន្ធ១** គឺអវិជ្ជា១, តណ្ហា១, កម្ម១, ផស្សៈ១, និព្វត្តិលក្ខណៈ១។

**លក្ខណៈ៥រលត់នៃវេទនាខន្ធ១, សញ្ញាខន្ធ១, សង្ខារក្ខន្ធ១** គឺរលត់អវិជ្ជា-តណ្ហា១-កម្ម១-ផស្សៈ១ វិបរិណាមលក្ខណៈ១។

**លក្ខណៈ៥កើតនៃវិញ្ញាណក្ខន្ធ**គឺអវិជ្ជា១,តណ្ហា១, កម្ម១, នាមរូប១, និព្វត្តិលក្ខណៈ១។

**លក្ខណៈ៥រលត់វិញ្ញាណក្ខន្ធ** គឺរលត់អវិជ្ជា១, តណ្ហា១, កម្ម១, នាមរូប១, វិបរិណាមលក្ខណៈ១ ។ ការពិចារណាឃើញនូវលក្ខណៈ ៥កើត និង ៥រលត់នេះ ឈ្មោះថាបានធ្វើទុកក្នុងចិត្តនូវ កិរិយាកើត និង កិរិយារលត់នៃខន្ធ៥ ដោយបច្ច័យផង ខណៈផង ។ លក្ខណៈក្នុងខន្ធមួយៗមាន១០, ខន្ធ៥ត្រូវជា ៥០ ( ១០ x ៥ = ៥០ ) ។ ( ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ៣)

## មហាវិបស្សនា ១៨

## មហាវិបស្សនាមាន ១៨គឺ

១-**អនិច្ចានុបស្សនា** ដែលលះបង់នូវនិច្ចសញ្ញា,

២-**ទុក្ខានុបស្សនា** ដែលលះបង់នូវសុខសញ្ញា,

៣-**អនត្តានុបស្សនា** ដែលលះបង់នូវអត្តសញ្ញា,

៤- **និព្វិទានុបស្សនា** ដែលលះបង់នូវនន្ទិ,

៥- **វិរាគានុបស្សនា** ដែលលះបង់នូវរាគៈ,

៦- **និរោធានុបស្សនា** ដែលលះបង់នូវសមុទយៈ,

៧- **បដិនិស្សគ្គានុបស្សនា** ដែលលះបង់នូវអាទានៈ,

៨-**ខយានុបស្សនា** ដែលលះបង់នូវឃនសញ្ញា, (សេចក្តីសម្គាល់ជាដុំ),

៩-**វយានុបស្សនា** ដែលលះបង់នូវអាយូហនៈ (ការប្រមូលមក),

១០-**វិបរិណាមានុបស្សនា** ដែលលះបង់នូវធុវសញ្ញា (សេចក្តីសម្គាល់ថាទៀង),

១១-**អនិមិត្តានុបស្សនា** ដែលលះបង់នូវមិត្ត (និមិត្ត),

១២-**អប្បណិហិតានុបស្សនា** ដែលលះបង់នូវបណិធិ

( ការតម្កល់ ) ។

១៣-**សុញ្ញតានុបស្សនា** ដែលលះបង់នូវអភិនិវេស (សេចក្តីប្រកាន់មាំ ) ។

១៤-**អធិប្បញ្ញាធម្មវិបស្សនា** ដែលលះបង់នូវសារាទានភិនិវេស(សេចក្តីប្រកាន់មាំថាមានខ្លឹមសារ) ។

១៥-**យថាភូតញ្ញាណទស្សនះ** ដែលលះបង់នូវសម្មោហាភិនិវេស, (សេចក្តីប្រកាន់មាំដោយសេចក្តីវង្វេង) ។

១៦-**អាទីនវានុបស្សនា** ដែលលះបង់នូវអាលយាភិនិវេស(សេចក្តីប្រកាន់មាំដោយសេចក្តីអាល័យ) ។

១៧-**បដិសង្ខានុបស្សនា** ដែលលះបង់នូវអបដិសង្ខារ (ការមិនពិចារណា) ។

១៨-**វិវដ្តានុបស្សនា** ដែលលះបង់នូវសំយោ-គាភិនិវេស (សេចក្តីប្រកាន់មាំនូវធម៌ដែលប្រកប) ។

**មហាវិបស្សនា១៨** នេះ គឺព្រះយោគីបានសម្រេចដោយប្រការទាំងអស់ ដោយអំណាចនៃ **បហានបរិញ្ញា** ។

**បហានបរិញ្ញា** នោះមានន័យថា បញ្ញាលះបង់រាប់ចាប់អំពីបាន **ភង្គានុបស្សនា** ឡដ៏ខាងលើតទៅ ។

កាលដែលព្រះយោគី បានចម្រើននូវសម្មសនញ្ញាណនិងឧទយព្វយានុបស្សនានេះ រមែងបានសម្រេចនូវមហាវិបស្សនានេះដោយប្រការខ្លះ ។

(ដកពីគម្ពីរវិសុទ្ធមគ្គភាគ ៣)

## IX- **វិបស្សនូបក្កិលេស ១០ និង ៣០ និង ការលះបង់ដោយត្រៃលក្ខណ៍**

**វិបស្សនូបក្កិលេស ១០** តែងកើតឡើង ដល់ **អារទ្ធវិបស្សកោ** យោគីដែលមានវិបស្សនានៅខ្ចី ។

**វិបស្សនូបក្កិលេស ១០គឺ**

១-**ឱភាសៈ** ពន្លឺភ្លឺស្វាងដ៏ក្រៃលែងជាងកាលមុន

២-**ញាណ** បញ្ញាកើតក្លៀវក្លា

៣-**បីតិ** សេចក្តីឆ្អែតកាយ-ចិត្ត បានដល់បីតិ៥ មានឧទ្ទកាបីតិជាដើម ។

៤-**បស្សទ្ធិ** សេចក្តីស្ងប់កាយ-ចិត្ត

៥-**សុខៈ** សេចក្តីសុខកាយ-ចិត្តដ៏ក្រៃលែង

៦-**អធិមោក្ខៈ** ជំនឿដ៏មានកម្លាំង

៧-**បគ្គាហៈ** សេចក្តីព្យាយាមមាំ

៨-**ឧបដ្ឋាន** ស្មារតីតាំងមាំក្លៀវក្លា

៩-**ឧបេក្ខា** ធម្មជាតិមានភាពកណ្តាលស្មើចំពោះសង្ខារទាំងពួង ។

១០-**និកន្តិ** សុខុមតណ្ហាកើតឡើងក្នុងរូបនិមិត្ត ដែលមាន ជាអានិសង្សរបស់វិបស្សនា។

## វិបស្សនូបក្កិលេស ៣០

**វិបស្សនូបក្កិលេស ៣០** នោះគឺ យកវិបស្សនូបក្កិលេស ១០ គុណនឹងធម៌៣ត្រូវជា ៣០( ១០ x ៣ = ៣០) ។ ធម៌៣នោះគឺ **ទិដ្ឋិ**( សេចក្តីយល់) ១ **មានះ**( សេចក្តីប្រ-កាន់) ១ **តណ្ហា** ( សេចក្តីប្រាថ្នា) ១

# ការលះបង់វិបស្សនូបក្កិលេស

កាលបើវិបស្សនូបក្កិលេស១០នេះណាមួយកើតឡើង ព្រះយោគីគប្បីពិចារណាថា " **នេតំ មម** នេះមិនមែនរបស់អញទេ **នេសោហមស្មិ** នុ៎ះមិនមែនជាអញទេ **នមេសា អត្តា** នុ៎ះមិនមែនជាខ្លួនអញ ឡើយ " ។

( ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ៣)

## X- **ប្រតិបត្តិតាមវិបស្សនាញាណ៩**

១-**ឧទយព្វយានុបស្សនាញាណ** បញ្ញាពិចារណានូវកិរិយាកើតនិងកិរិយារលត់នៃសង្ខារ ។

២-**ភង្គានុបស្សនាញាណ** បញ្ញាពិចារណានូវកិរិយាបែកធ្លាយនៃសង្ខារ ។

៣-**ភយតុបដ្ឋានញាណ** បញ្ញាពិចារណាឃើញទោសនៃសង្ខារប្រាកដឡើងថាគួរខ្លាច ។

៤-**អាទីនវានុបស្សនាញាណ** បញ្ញាពិចារណាឃើញទោសនៃសង្ខារ ។

៥-**និព្វិទានុបស្សនាញាណ**បញ្ញាពិចារណានឿយណាយឃើញទោសក្នុងបញ្ចក្ខន្ធ ។

៦-**មុញ្ចិតុកម្យតាញាណ** បញ្ញាប្រាថ្នានឹងចង់រួចចាកបញ្ចក្ខន្ធ ។

៧-**បដិសង្ខានុបស្សនាញាណ** បញ្ញាពិចារណារកឧបាយដែលនឹងដោះខ្លួនឱ្យរួចចាកខន្ធ ។

៨-**សង្ខារុបេក្ខាញាណ** បញ្ញាតាំងឧបេក្ខាក្នុងសង្ខារ

៩-**សច្ចានុលោមិកញ្ញាណ** បញ្ញាដែលប្រព្រឹត្តទៅតាមសមគួរដល់សច្ចធម៌ ។ **សច្ចានុលោមិកញ្ញាណ**នេះ គឺជាអនុលោមញាណ ហ្នឹងឯង ។ (ដកពីគម្ពីរវិសុទ្ធិមគ្គភាគ៣)

## XI- **អរិយសច្ច ៤**

**អរិយសច្ច** មានន័យថាធម៌ពិតដ៏ប្រសើរមាន៤យ៉ាងគឺ ទុក្ខអរិយសច្ច១ ទុក្ខសមុទយអរិយសច្ច១ ទុក្ខនិរោធអរិយសច្ច១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច១ ។

-**ទុក្ខអរិយសច្ច** មានន័យថា ធម៌ពិតដ៏ប្រសើរជាទុក្ខ ។

-**ទុក្ខសមុទយអរិយសច្ច**មានន័យថា ធម៌ពិតដ៏ប្រសើរជាហេតុនាំឱ្យកើតទុក្ខ ។

-**ទុក្ខនិរោធអរិយសច្ច** មានន័យថា ធម៌ពិតដ៏ប្រសើរជាធម៌រំលត់នូវសេចក្ដីទុក្ខ ។

-**ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច**ធម៌ពិត ដ៏ប្រសើរជាផ្លូវប្រតិបត្តិដើម្បីកិរិយាដល់នូវព្រះនិព្វានជាទីរំលត់នូវសេចក្ដីទុក្ខ ។

## **អត្ថរបស់អរិយសច្ច**

**អរិយសច្ច** មួយៗមានអត្ថ៤ រួមទាំងអស់មានអត្ថ ១៦ ( ៤ x ៤ = ១៦ )

**អរិយសច្ចៈ** មាន **បរិវដ្ដ ៣** មាន **អាការៈ១២**

**បរិវដ្ដ ៣ គឺ**

**១-សច្ចញ្ញាណ** ប្រាជ្ញាស្ទង់ដឹងអរិយសច្ច

**២-កិច្ចញ្ញាណ** ប្រាជ្ញាស្ទង់ដឹងកិច្ចដែលគួរធ្វើ

**៣-កតញ្ញាណ** ប្រាជ្ញាស្ទង់ដឹងកិច្ចដែលធ្វើហើយ

**អាការៈ ១២គឺ**

អរិយសច្ចមួយមាន បរិវដ្ដ ឬញាណ ៣។ រួមទាំងអស់មាន ១២ ដែលហៅថា អាការៈ ១២ ( ៣ x ៤ = ១២ ) ។

( ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ៣ )

## XII- **មគ្គ៤ ផល៤ និព្វាន ១-២-៣**

### មគ្គ ៤

-មគ្គ មានន័យថាផ្លូវ បានដល់កិរិយាស្វែងរកនូវព្រះនិព្វានមាន ៤គឺ

**១- សោតាបត្តិមគ្គ :** មានន័យថា មគ្គ[៣] នៃបុគ្គលដែលដល់ហើយក្នុងដើមនៃធមិដូចជាខ្សែឈ្មោះ **សោតៈ** ។

**២-សកទាគាមិមគ្គ** មានន័យថា មគ្គនៃបុគ្គលដែលមកកាន់មនុស្សលោកនេះ អស់វារៈម្តងដោយអំណាចនៃបដិសន្ធិ។

**៣-អនាគាមិមគ្គ** មានន័យថាមគ្គនៃបុគ្គល ដែលមិនមកកាន់កាមធាតុឰដ៏ខាងក្រោម ដោយអំណាច

---

[៣] មគ្គចិត្ត ចិត្តដែលសម្បយុត្តដោយមគ្គ

បដិសន្ធិឡើយ ។

**៤-អរហត្តមគ្គ** មគ្គនៃបុគ្គលមានកិរិយាធ្វើនូវបាបកម្មក្នុងទីស្ងាត់មិនមាន ។

**ផល ៤**

**- ផល** មានន័យថា ផលបានដល់សេចក្ដីសម្រេចនូវព្រះនិព្វាន មាន ៤ គឺ

**១-សោតាបត្តិផល** មានន័យថា ផល[៤] នៃបុគ្គលដែលដល់ហើយក្នុងដើមនៃធម៌ដូចជាខ្សែឈ្មោះ**សោត** ។

**២-សកទាគាមិផល** មានន័យថា ផលនៃបុគ្គលដែលមកកាន់មនុស្សលោកនេះ អស់វារៈម្ដងដោយអំណាច

---

[៤] ផលចិត្ត ចិត្តដែលសម្បយុត្តដោយផល

នៃ **បដិសន្ធិ** ។

**៣-អនាគាមិផល** មានន័យថា ផលនៃបុគ្គលដែលមិនមកកាន់កាមធាតុឮដ៏ខាងក្រោម ដោយអំណាច **បដិសន្ធិ** ឡើយ ។

**៤-អរហត្តផល** មានន័យថាផលនៃបុគ្គលមានកិរិយាធ្វើនូវបាបកម្មក្នុងទីស្ងាត់មិនមាន ។

(ដកពីគម្ពីរអភិធម្មត្ថសង្គហ)

## និព្វាន ១-២-៣

**និព្វាន** មានន័យថា មិនមានព្រៃ ពោលគឺតណ្ហា ព្រះនិព្វាននោះជាអារម្មណ៏របស់ **មគ្គចិត្ត** និង **ផលចិត្ត** ។

## ព្រះនិព្វានមានប្រការ១គឺពោលតាមសភាវៈ

## និព្វាន ២គឺ

**១-សឧបាទិសេសនិព្វាន** រលត់តែកិលេស បញ្ចក្ខន្ធនៅសល់

**២-អនុបាទិសេសនិព្វាន** រលត់ទាំងកិលេសទាំងបញ្ចក្ខន្ធ។ ព្រះនិព្វានដែលមានប្រការ២នេះ គឺលោកពោលដោយការបរិយាយ។

## និព្វាន ៣

**១-សុញ្ញតនិព្វាន**

**២-អនិមិត្តនិព្វាន**

**៣-អប្បណិហិតនិព្វាន**

ព្រះនិព្វានដែលមានប្រការ ៣ នេះ គឺលោកពោលតាមប្រភេទនៃអាការ។ ( ដកពីគម្ពីរអភិធម្មត្ថសង្គហ)

## XIII- បច្ចវេក្ខណញ្ញាណ ១៩

**បច្ចវេក្ខណញ្ញាណ១៩** នោះគឺលោកចែកទៅតាមថ្នាក់ព្រះអរិយបុគ្គល

**-ព្រះសោតាបន្ន** មានបច្ចវេក្ខណញ្ញាណ ៥

**-ព្រះសកទាគាមិ** មានបច្ចវេក្ខណញ្ញាណ ៥

**-ព្រះអនាគាមិ** មានបច្ចវេក្ខណញ្ញាណ ៥

**-ព្រះអរហន្ត** មានបច្ចវេក្ខណញ្ញាណ ៤ រួមជាបច្ចវេក្ខណញ្ញាណ ១៩

**សោតាបន្នមានបច្ចវេក្ខណញ្ញាណ ៥ នោះគឺ**

**១-មគ្គប្បច្ចវេក្ខណៈ** ញាណពិចារណាឃើញច្បាស់នូវមគ្គ។

**២-ផលប្បច្ចវេក្ខណៈ** ញាណពិចារណាឃើញច្បាស់

នូវផល ។

**៣-បហីនប្បច្ចវេក្ខណៈ** ញាណពិចារណាឃើញច្បាស់នូវកិលេសដែលលះបង់បានហើយ ។

**៤-អវសិដ្ឋប្បច្ចវេក្ខណៈ** ញាណពិចារណាឃើញច្បាស់នូវកិលេសដែលនៅសល់ ។

**៥-និព្វានប្បច្ចវេក្ខណៈ** ញាណពិចារណាឃើញច្បាស់នូវព្រះនិព្វាន ឯព្រះសកទាគាមិនិងព្រះអនាគាមិមានបច្ចវេក្ខណញ្ញាណ៥៧ដូចគ្នា។ ចំណែកព្រះអរហន្តមានបច្ចវេក្ខណញ្ញាណតែ៤ ព្រោះលោកពុំមានកិលេសសល់នៅដូចសេក្ខបុគ្គលឡើយ ។

(ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ៣)

## សិក្សាអំពីកិលេស និងធម៌បន្ថែម

**១-នីវរណធម៌៥ កិលេស៣ ឧបក្កិលេស១៦ នីវរណៈ ៥**

**នីវរណធម៌** មានន័យថា ធម៌ជាគ្រឿងរារាំងចិត្តមិនឱ្យកសាងនូវកុសលមាន៥ យ៉ាងគឺ

**កាមឆន្ទៈ១, ព្យាបាទ១, ថីនមិទ្ធ១, ឧទ្ធច្ចកុក្កុច្ចៈ១, វិចិកិច្ឆា១ ។**

(សេចក្តីប្រែក្នុងគោលធម៌មធ្យមវិបស្សនា)

(ដកពីគម្ពីរវិសុទ្ធិមគ្គភាគ ១)

**កិលេស ៣**

**កិលេស** មានន័យថា ធម្មជាតិជាគ្រឿងសៅហ្មងមាន ៣ យ៉ាង

**១-រាគៈ** សេចក្តីតម្រេក

**២-ទោសៈ** ប្រទូស្តក្នុងអារម្មណ៏

**៣-មោហៈ** វង្វេងក្នុងអារម្មណ៏

(ដកក្នុងព្រះសូត្រ)

## ឧបក្កិលេស ១៦

**ឧបក្កិលេស**មានន័យថាទោសជាគ្រឿងសៅហ្មង មាន ១៦ យ៉ាងគឺ

**១-អភិជ្ឈាវិសមលោភៈ** លោភមិនស្មើ គឺ គយគន់រំពៃចង់បានមិនរើសមុខ

**២-ទោសៈ** គិតប្រទូស្ត

**៣-កោធៈ** ក្រោធ

**៤-ឧបនាហៈ** ចងក្រោធទុក

**៥-មក្ខៈ** រមិលគុណ

**៦-មលាសៈ** ធ្វើខ្លួនស្មើ គឺលើកខ្លួនផ្ទឹមនឹងអ្នកខ្ពង់ខ្ពស់

**៧-ឥស្សា** ឬស្សា គឺ សេចក្ដីច្រណែន ឈ្នានិស

**៨-មច្ឆរិយៈ** កំណាញ់

**៩-មាយា** មាយា គឺលាក់ពុតបាំងទោសខ្លួន

**១០-សាថេយ្យៈ** អ្នកអួតអាង

**១១-ថម្ភៈ** មុខរឹង

**១២-សារម្ភៈ** ប្រណាំងវាសនា

**១៣-មានះ** ប្រកាន់ខ្លួន

**១៤-អតិមានះ** មើលងាយគេ

**១៥-មទៈ** ស្រវឹង ( ក្នុង)

**១៦-បមាទៈ** ប្រហែសធ្វេស

( ដកក្នុងមជ្ឈិមនិកាយមូលបណ្ណាសក)

## ២-អនុសយ៧

**អនុសយ** មានន័យថាកិលេសដែលដេកត្រាំក្នុងសន្ដាន មាន ៧ យ៉ាងគឺ

**១-កាមរាគៈ** បានដល់សេចក្ដីតម្រេកក្នុងកាម ។

**២-បដិឃៈ** បានដល់សេចក្ដីចង្អៀតចង្អល់ ពោលដោយសេចក្ដី បានដល់ទោសៈ

**៣-ទិដ្ឋិ** បានដល់សេចក្ដីឃើញខុស

**៤-វិចិកិច្ឆា** បានដល់សេចក្ដីសន្ទិះសង្ស័យ

**៥-មានៈ** បានដល់សេចក្ដីប្រកាន់ខ្លួន ។

**៦-ភវរាគៈ** បានដល់សេចក្ដីតម្រេកក្នុងភព ឬ សេចក្ដីចង់កើត ។

**៧-អវិជ្ជា** បានដល់សេចក្ដីល្ងង់មិនដឹងតាមពិត ពោល

ដោយសេចក្ដីបានដល់មោហៈ។ កិលេស៧នេះ ពួកខ្លះជាអនុស័យរបស់បុគ្គលពួកខ្លះហៅថាសំយោជន៧ក៏បាន (ដកពីគម្ពីរអភិធម្មត្ថសង្គហ)

## ៣- សំយោជន ១០

**សំយោជនៈ** មានន័យថា កិលេសដែលចងចិត្តសត្វទុកក្នុង **វដ្តៈ** មាន១០យ៉ាងគឺ

**១-សក្កាយទិដ្ឋិ** សេចក្ដីឃើញដែលប្រកាន់ថាបញ្ចក្ខន្ធជារបស់ផងខ្លួន

**២-វិចិកិច្ឆា** សេចក្ដីស្ទាក់ស្ទើរជាហេតុមិនប្រាកដក្នុងចិត្ត។

**៣-សីលព្វត្តបរាមាស** សេចក្ដីជឿប្រកាន់ស័ក្តិសិទ្ធិដោយ ចូលចិត្តថា អាចបានដោយសីល ឬ

វត្ថុយ៉ាងនោះៗ ។

**៤-កាមរាគៈ**តម្រេកដោយអំណាចកិលេសកាម ។

**៥-បដិឃៈ** សេចក្តីខ្ញាំងខ្ញុប់នៃចិត្ត ។ ៥នេះជាសំយោជនៈខាងក្រោម គឺយ៉ាងជ្រោកជ្រាកហៅថា **ឱរម្ភាគិយ** ។

**៦-រូបរាគៈ** សេចក្តីជាប់ចិត្តក្នុងរូបធម៌

**៧-អរូបរាគៈ** សេចក្តីជាប់ចិត្តក្នុងអរូបធម៌

**៨-មានៈ** សេចក្តីសម្គាល់ខ្លួនថា ជានេះ ជានោះ

**៩-ឧទ្ធច្ចៈ** សេចក្តីអណ្តែតអណ្តូងនៃចិត្ត

**១០-អវិជ្ជា** សេចក្តីវង្វេង ដែលជាហេតុមិនឱ្យដឹងពិត

៥នេះជាសំយោជនខាងលើ គឺ យ៉ាងល្អិតហៅថា

**ឧទ្ធម្ភាគិយ** ។ (សំយោជន១០នេះក្នុងព្រះសូត្រ)

**សំយោជន ១០ ទៀត**

**កាមរាគៈ១ បដិឃៈ១ មានៈ១ ទិដ្ឋិ១ វិចិកិច្ឆា១**

**សីលព្វត្តបរាមាសៈ១ ភវរាគៈ១ ឥស្សា ១ មច្ឆរិយ ១**

**អវិជ្ជា ១ ។**

សំយោជនៈ ១០ នេះក្នុងអភិធម្ម ។

(ដកពីគម្ពីរ អភិធម្មត្ថសង្គហ)

**៤-អវិជ្ជា ៨, តណ្ហា ១០៨**

**អវិជ្ជា ៨**

១-ការមិនដឹងក្នុងទុក្ខ

២-ការមិនដឹងក្នុងហេតុកើតនៃទុក្ខ

៣- ការមិនដឹងក្នុងការរំលត់ទុក្ខ

៤- ការមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ

៥-ការមិនដឹងក្នុងខន្ធ ជាចំណែកខាងដើម គឺ ក្នុងអតីត

៦-ការមិនដឹងក្នុងខន្ធ ជាចំណែកខាងចុងគឺ ក្នុងអនាគត

៧-ការមិនដឹងក្នុងខន្ធ ជាចំណែកខាងដើម និងខាងចុង

៨-ការមិនដឹងក្នុងពួកធម៌ ដែលកើតឡើងព្រោះអាស្រ័យបច្ច័យនោះៗ

(ដកពីគម្ពីរវិសុទ្ធិមគ្គ ភាគ ៣)

## តណ្ហា ១០៨

### តណ្ហា ៣ គឺ

**១-កាមតណ្ហា** តណ្ហាក្នុងកាម

**២-ភវតណ្ហា** តណ្ហាក្នុងភព

**៣-វិភវតណ្ហា** តណ្ហាក្នុងការប្រាសចាកភព តណ្ហា១០៨នោះ គឺ យកតណ្ហា៣ គុណនឹងអាយតនៈខាងក្នុង៦ត្រូវជា ១៨( ៦ x ៣ = ១៨) យកតណ្ហា ៣ គុណនឹងអាយតនៈខាងក្រៅ ៦ ត្រូវ១៨ ( ៦ x ៣ = ១៨ ) រួមតណ្ហាទាំងខាងក្នុង នឹងខាងក្រៅត្រូវជា៣៦ តណ្ហា( ១៨ +១៨=៣៦) តណ្ហា៣៦នេះ ចាត់ជាតណ្ហាក្នុងបច្ចុប្បន្ន យកតណ្ហា ៣៦ ក្នុងអតីត និង តណ្ហា ៣៦ក្នុងអនាគត មករួមត្រូវជា ១០៨ តណ្ហា

( ៣៦ + ៣៦ + ៣៦ = ១០៨)

( ដកពីគម្ពីរវិសុទ្ធិមគ្គភាគ៣ )

## ៥-បហាន ៣

**១- តទង្គប្បហាន** ការលះបង់បាន១គ្រា

**២-វិក្ខម្ភនប្បហាន** ការលះបង់ដោយសង្កត់ទុកឃ្ញូរ

**៣-សមុច្ឆេទប្បហាន** ការលះបង់បានដាច់ស្រឡះ

(ដកពីគម្ពីរវិសុទ្ធិមគ្គ)

## ៦-ពោធិបក្ខិយ ៣៧

**ពោធិបក្ខិយធម៌** មានន័យថា ធម៌ជាផ្នែកជាគ្រឿងឱ្យត្រាស់ដឹង មាន ៣៧ គឺ

**សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គ** ប្រកបដោយអង្គ **៨** ។

### សតិបដ្ឋាន ៤ គឺ

**១-កាយានុបស្សនា** សតិរលឹកពិចារណាកាយជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយប៉ុណ្ណោះ មិនមែនជាសត្វ ជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ

ជាយើង ជាគេឡើយ ។

**២- វេទនានុបស្សនា** សតិរលឹកពិចារណាវេទនាគឺសេចក្តី សុខ ទុក្ខ ឧបេក្ខា ជាអារម្មណ៍ វេទនាគ្រាន់តែជាវេទនាប៉ុណ្ណោះមិនមែន ជាសត្វ ជាបុគ្គលជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

**៣- ចិត្តានុបស្សនា** សតិរលឹកពិចារណាចិត្តដែលសៅហ្មង និង ផូរផង់ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គលជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

**៤-ធម្មានុបស្សនា** សតិរលឹកពិចារណាធម៌ជាកុសល ឬ អកុសលដែលកើតឡើងជាមួយចិត្ត ជាអារម្មណ៍ថាធម៌នេះ គ្រាន់តែជាធម៌ប៉ុណ្ណោះ មិនមែន

ជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

## សម្មប្បធាន ៤

**១- សំវរប្បធាន** ព្យាយាមប្រយ័ត្ន មិនឱ្យបាបកើតឡើងក្នុងសន្ដាន ។

**២-បហានប្បធាន** ព្យាយាមលះបាបដែលកើតឡើង ។

**៣-ភាវនាបធាន** ព្យាយាមញ៉ាំងកុសលឱ្យកើតក្នុងសន្ដាន ។

**៤-អនុរក្ខនាបធាន** ព្យាយាមរក្សាកុសលដែលកើតមានឡើងហើយ មិនឱ្យសាបសូន្យទៅវិញ

## ឥទ្ធិបាទ ៤

**១- ឆន្ទសមាធិ** សមាធិ ដោយមានឆន្ទះជា ប្រធាន

**២-វីរិយសមាធិ** សមាធិ ដោយមានវីរិយជាប្រធាន

**៣-ចិត្តសមាធិ** សមាធិ ដោយមានចិត្តជាប្រធាន

**៤-វិមំសាសមាធិ** សមាធិ ដោយមានបញ្ញាជាប្រធាន

## ឥន្ទ្រិយ ៥

**១-សទ្ធិន្ទ្រិយ** ឥន្ទ្រិយ គឺសទ្ធា (ជឿជាក់)

**២-វីរិយិន្ទ្រិយ** ឥន្ទ្រិយ គឺវីរិយៈ

**៣-សតិន្ទ្រិយ** ឥន្ទ្រិយ គឺសតិ

**៤-សមាធិន្ទ្រិយ** ឥន្ទ្រិយ គឺសមាធិ

**៥-បញ្ញិន្ទ្រិយ** ឥន្ទ្រិយ គឺបញ្ញា។

## ពលៈ ៥

**១- សទ្ធាពលៈ** កម្លាំង គឺសទ្ធា

**២-វិរិយពលៈ** កម្លាំង គឺសេចក្តីព្យាយាម

**៣-សតិពលៈ** កម្លាំង គឺសតិ ( ស្មារតី)

**៤-សមាធិពលៈ** កម្លាំង គឺចិត្តតម្កល់

**៥-បញ្ញាពលៈ** កម្លាំង គឺប្រាជ្ញា ។

## សម្ពោជ្ឈង្គ ៧

**-សម្ពោជ្ឈង្គ** មានន័យថា អង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹងពិត មាន ៧យ៉ាងគឺ

**១-សតិ** សេចក្តីរលឹកបាន

**២-ធម្មវិចយ** សេចក្តីពិចារណាជ្រើសរើសធម៌

**៣-វិរិយ** សេចក្តីព្យាយាម

**៤-បីតិ** សេចក្ដីឆ្អែតចិត្ត

**៥-បស្សទ្ធិ** សេចក្ដីស្ងប់ចិត្ត

**៦-សមាធិ** សេចក្ដីតាំងចិត្តខ្ជាប់

**៧-ឧបេក្ខា** សេចក្ដីតាំងចិត្តព្រងើយ

ហៅតាមប្រភេទថា **សតិសម្ពោជ្ឈង្គ** ដោយលំដាប់ដល់ **ឧបេក្ខាសម្ពោជ្ឈង្គ** ។

## មគ្គមានអង្គ ៨

**១-សម្មាទិដ្ឋិ** បញ្ញាឃើញប្រពៃ គឺឃើញអរិយសច្ច៤ ។

**២-សម្មាសង្កប្បៈ** ត្រិះរិះប្រពៃ គឺត្រិះរិះនឹងចេញចាកកាម១ ត្រិះរិះក្នុងការមិនជាហេតុឱ្យកើតព្យាបាទ១ ត្រិះរិះក្នុងការមិនជាហេតុបៀតបៀន១

**៣-សម្មាវាចា** វាចាប្រពៃ គឺវៀរចាកកាយទុច្ចរិត ៤

**៤-សម្មាកម្មន្ត** ការងារត្រូវ គឺវៀរចាកកាយទុច្ចរិត ៣

**៥-សម្មាអាជីវ** ចិញ្ចឹមជីវិតប្រពៃ គឺវៀរចាកការចិញ្ចឹមជីវិតដោយផ្លូវខុស

**៦- សម្មាវាយាមៈ** ព្យាយាមប្រពៃ គឺសម្មប្បធាន ៤

**៧- សម្មាសតិ** រលឹកប្រពៃ គឺរលឹកក្នុងសតិប្បដ្ឋាន៤

**៨-សម្មាសមាធិ** តាំងចិត្តខ្ជាប់ប្រពៃ គឺចម្រើន ឈាន៤

ក្នុងអង្គមគ្គ៨នេះ សម្មាទិដ្ឋិ១ សម្មាសង្កប្បៈ១ សង្គ្រោះចូលក្នុងបញ្ញាសិក្ខា, សម្មាវាចា១ សម្មាកម្មន្តៈ១ សម្មាអាជីវៈ១ សង្គ្រោះចូលក្នុងសីលសិក្ខា, សម្មាវាយាម១ សម្មាសតិ១ សម្មាសមាធិ១ សង្គ្រោះចូលក្នុងចិត្តសិក្ខា ។

(ដកពីសំយុត្តនិកាយមហាវារវគ្គ)